# ស្ត្រីអិល.ឌី.អេស.គឺអស្ចារ្យណាស់ !

អែលឌើរ ឃ្វីនថិន អិល ឃុក
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*អ្វីៗជាច្រើនដែលយើងសម្រេចបាននៅក្នុងសាសនាចក្រនេះគឺដោយសារការបម្រើដ៏ឥតសំចៃនៃស្ត្រី ។*

វ៉ល្លិន ស្តេគណឺ ជាអ្នកនិពន្ធ និងជាអ្នកប្រវត្តិសាស្ត្របានសរសេរពីការធ្វើអន្តោប្រវេសន៍ និងការប្រមូលផ្តុំគ្នានៃពួកមរមនទៅជ្រលងភ្នំសលត៍លេក ។ គាត់មិនទទួលស្គាល់សាសនាយើង ហើយក៏បានរិះគន់នូវរឿងជាច្រើន តែគាត់បានកោតសរសើរដល់ការលះបង់ និងភាពអង់អាចនៃសមាជិកសាសនាចក្រយើងកាលពីមុន ជាពិសេសគឺស្ត្រី ។ គាត់បានលើកឡើងថា « ស្ត្រីរបស់គេគឺអស្ចារ្យណាស់ ! »[1] ថ្ងៃនេះខ្ញុំសូមបន្លឺនូវពាក្យពេចន៍ដូចគ្នានេះ ។ ស្ត្រីអិល.ឌី.អេស.យើងគឺអស្ចារ្យណាស់ !

ព្រះបានផ្តល់ឲ្យស្ត្រីនូវគុណសម្បត្តិដ៏ទេវភាពនៃភាពរឹងមាំ គុណធម៌ សេចក្តីស្រឡាញ់ និងឆន្ទៈលះបង់ដើម្បីចិញ្ចឹមជំនាន់នាអនាគតនៃកូនចៅវិញ្ញាណទ្រង់ ។

ការសិក្សាមួយថ្មីៗនេះក្នុងសហរដ្ឋអាមេរិកអះអាងថា ស្ត្រីគ្រប់សាសនាទាំងអស់ « ជឿដល់ព្រះយ៉ាងខ្លាំង » ហើយចូលរួមកម្មវិធីសាសនាច្រើន ។ « គេជឿលើសាសនាយ៉ាងខ្លាំង ស្ទើរតែរាល់វិធីទាំងអស់ » ។[2]

ខ្ញុំពុំភ្ញាក់ផ្អើលចំពោះលទ្ធផលនេះឡើយ ជាពិសេស ពេលខ្ញុំគិតពីតួនាទីដ៏អស្ចារ្យនៃគ្រួសារ និងស្ត្រីក្នុងសាសនាយើង ។ គោលលទ្ធិយើងមានភាពច្បាស់លាស់ ។ ស្ត្រីជាបុត្រីនៃព្រះវរបិតាសួគ៌យើង ហើយទ្រង់ស្រឡាញ់ពួកគេ ។ ភរិយាមានសិទ្ធិស្មើនឹងស្វាមីខ្លួន ។ អាពាហ៍ពិពាហ៍ត្រូវការភាពជាដៃគូមួយពេញលេញ ដែលភរិយានិងស្វាមីចាប់ដៃគ្នាដើម្បីបំពេញតម្រូវការនៃគ្រួសារ ។[3]

យើងដឹងថាមានឧបសគ្គជាច្រើនចំពោះស្ត្រី រួមទាំងការព្យាយាមរស់នៅតាមដំណឹងល្អផងដែរ ។ ឥរិយាបថដ៏សំខាន់នៅក្នុងជីវិតនៃអ្នកត្រួសត្រាយផ្លូវពីមុនរបស់យើងគឺជាសេចក្តីជំនឿនៃបងប្អូនស្រីទាំងឡាយ ។ ដោយនិស្ស័យដ៏ទេវភាព ស្ត្រីមានអំណោយទាន និងទំនួលខុសត្រូវដ៏ធំចំពោះគ្រួសារ និងកូន និងចំពោះការបីបាច់ក្នុងគ្រួសារ និងកន្លែងផ្សេងទៀត ។ ដោយពិចារណាពីសេចក្តីជំនឿនេះរបស់បងប្អូនស្រីដែលព្រមចាកចេញពីផ្ទះខ្លួនឆ្លងកាត់ទីវាល ហើយប្រឈមមុខនឹងអនាគតដែលមិនស្គាល់ ។ បើមនុស្សម្នាក់ចង់ស្វែងរកគុណសម្បត្តិដ៏សំខាន់របស់គេ នោះប្រាកដជាសេចក្តីជំនឿដ៏មុតមាំរបស់គេនៅក្នុងដំណឹងល្អនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ។

ដំណើររឿងដ៏អង់អាចពីអ្វីដែលស្ត្រីត្រួសត្រាយផ្លូវទាំងនេះបានលះបង់ និងសម្រេចបាន ពេលពួកគេបានឆ្លងកាត់ទីវាល គឺជាមរតកដ៏មានតម្លៃចំពោះសាសនាចក្រ ។ ខ្ញុំមានចិត្តក្តុកក្តួលក្នុងដំណើររឿងនៃអេលីហ្សាប៊េត ចាកសិន ដែលស្វាមីរបស់នាង ឈ្មោះ អេរ៉ុន បានស្លាប់ក្រោយពីការឆ្លងកាត់ចុងក្រោយទៅទន្លេ ផ្លាជាមួយនឹងក្រុមរទេះរុញម៉ាទីន ។ នាងបានសរសេរថា ៖ « ខ្ញុំមិនចង់រៀបរាប់ពីអារម្មណ៍ខ្ញុំពេលខ្ញុំក្លាយជាស្ត្រីមេម៉ាយម្នាក់ ដែលមានកូនបីនាក់ នៅក្នុងស្ថានភាពបែបនេះឡើយ ។... ខ្ញុំជឿ... ថាការរងទុក្ខរបស់ខ្ញុំដើម្បីដំណឹងល្អនឹងត្រូវបានគេចាត់ទុកជាទង្វើមួយដ៏បរិសុទ្ធសម្រាប់សេចក្តីល្អ ... ។ ខ្ញុំ[ បានអំពាវនាវ ] រកព្រះអម្ចាស់ ...ជាអង្គដែលបានសន្យាថានឹងធ្វើជាស្វាមីដល់ស្ត្រីមេម៉ាយ និងជាឪពុកដល់កូនគ្មានឪពុក ។ ខ្ញុំបានអំពាវនាវរកទ្រង់ ហើយទ្រង់បានជួយខ្ញុំ » ។[4]

អេលីហ្សាប៊េត បាននិយាយថា គាត់កំពុងសរសេរប្រវត្តិសាស្ត្រនេះ ជាប្រយោជន៍ដល់អ្នកដែលឆ្លងកាត់ស្ថានភាពដូចគ្នានេះ ដោយសង្ឃឹមថាជំនាន់នាអនាគតនឹងព្រមទទួលយកនូវការរងទុក្ខ ។[5]

ខ្ញុំជឿថាស្ត្រីក្នុងសាសនាចក្រសព្វថ្ងៃនេះ បានបំពេញតាមសំណូមពរនោះ ហើយមានភាពរឹងមាំនិងស្មោះត្រង់ ។អ្នកដឹកនាំបព្វជិតភាពគ្រប់ជាន់ថ្នាក់នៅក្នុងសាសនាចក្រនេះបានទទួលស្គាល់ពីការបម្រើ ការលះបង់ ការប្តេជ្ញាចិត្ត និងការបរិច្ចាគរបស់បងប្អូនស្រីទាំងឡាយ ។

អ្វីៗជាច្រើនដែលយើងសម្រេចបាននៅក្នុងសាសនាចក្រនេះគឺដោយសារការបម្រើដ៏ឥតសំចៃនៃស្ត្រី ។ មិនថាក្នុងសាសនាចក្រ ឬក្នុងផ្ទះទេ វាជាការល្អ ដោយឃើញបព្វជិតភាព និងសមាគមសង្គ្រោះធ្វើការក្នុងភាពសុខដុមដ៏ឥតខ្ចោះ ។ទំនាក់ទំនងមួយបែបនេះគឺប្រៀបដូចជាក្រុមភ្លេងដ៏ល្អ ហើយប្រគំជាបទភ្លេងដែលបំផុសគំនិតដល់យើងគ្រប់គ្នា ។

ថ្មីៗនេះ ពេលខ្ញុំត្រូវបានចាត់ឲ្យចូលរួមសន្និសីទនៅបេសកកម្មនៃស្តេក វីចូ កាលីហ្វ័រញ៉ាខ្ញុំបានជាប់ចិត្តនឹងរឿងមួយពីរបាំរួមគ្នានៃយុវវ័យក្នុងស្តេកចំនួនបួន នៅយប់មុនថ្ងៃចូលឆ្នាំថ្មី ។ ក្រោយពីរបាំនោះ គេបានរកឃើញកាបូបដៃមួយដែលគ្មានម្ចាស់ ។ ខ្ញុំសូមចែកចាយអ្នកនូវផ្នែកដែល បងស្រី ម៉ូនីកា សេដវីក ជាប្រធានយុវនារីក្នុងស្តេក ឡាហ្គូណា នីហ្គេលបានកត់ត្រាថា ៖

« យើងមិនចង់រុករើទេ ព្រោះនេះជារបស់អ្នកដទៃ ! ដូច្នេះ យើងបានបើកវាដោយប្រយ័ត្ន ហើយទាញយករបស់ដែលនៅលើគេបង្អស់ ---ដោយសង្ឃឹមថា វានឹងបញ្ជាក់ពីអត្តសញ្ញាណនាង ។ វាមាន ...តែវាបង្ហាញពីអ្វីផ្សេង ---វាជាកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ។...អស្ចារ្យណាស់ ! វាប្រាប់នូវអ្វីមួយពីនាងដល់យើង ។ រួចហើយយើងបានលូកយករបស់បន្ទាប់ ជាសៀវភៅកត់ត្រាតូចមួយ ...ពិតណាស់វាបានផ្តល់ចម្លើយដល់យើង ។តែពុំមែនជាចម្លើយដែលយើងចង់បានឡើយ ។ ទំព័រដំបូង ...គឺជាបញ្ជីនៃខគម្ពីរដែលចូលចិត្ត ...ហើយមានប្រាំទំព័រទៀតគឺជាខគម្ពីរនិងកំណត់ចំណាំផ្ទាល់ខ្លួនដែលបានសរសេរយ៉ាងផ្ចិតផ្ចង់ » ។

ភ្លាមនោះ បងប្អូនស្រីទាំងឡាយបានចង់ជួបនឹងយុវនារីដ៏ស្មោះត្រង់រូបនេះ ។ គេបានរករបស់ក្នុងកាបូបនោះដើម្បីស្គាល់ម្ចាស់វា ។ គេបានយកចេញនូវស្ករបំបាត់ក្លិនមាត់ សាប៊ូដុំ ឡេ និងច្រាស់ ។ ខ្ញុំចូលចិត្តពីពាក្យពេចន៍គេថា ៖ «អូ រឿងល្អកើតចេញពីមាត់នាង ។ នាងបានលាងសំអាតដៃ ហើយចេះមើលថែខ្លួនឯង » ។

គេអន្ទះសាចង់ឃើញរបស់បន្ទាប់ទៀត ។ វាគឺជាកាបូបដាក់កាក់ដែលធ្វើចេញពីប្រអប់ក្រដាសទឹកក្រូច ហើយវាមានប្រាក់មួយចំនួននៅក្នុងហោប៉ៅបិទរួតជិត ។ គេបានលាន់មាត់ថា « នាងចេះច្នៃប្រឌិតនិងចេះរៀបចំណាស់ ! » គេមានអារម្មណ៍ដូចជាក្មេងតូចៗនៅព្រឹកថ្ងៃគ្រីស្ទម៉ាស់អញ្ចឹងដែរ ។ អ្វីដែលគេដកយកចេញបន្ទាប់ធ្វើឲ្យគេភ្ញាក់ផ្អើលកាន់តែខ្លាំង ---វាគឺជារបៀបធ្វើនំសូកូឡាមួយប្រភេទនិងកំណត់ចំណាំមួយដើម្បីធ្វើនំនោះសម្រាប់ថ្ងៃកំណើតមិត្តម្នាក់ ។ គេស្ទើរតែស្រែកថា « នាងជាមេផ្ទះទៀត !! ចេះគិតគូរនិងមានចិត្តចង់បម្រើ » ។ នៅទីបំផុត គេបានរកឃើញអត្តសញ្ញាណមួយចំនួន ។ អ្នកដឹកនាំយុវវ័យទាំងនោះបាននិយាយថា គេមានអារម្មណ៍ថាមានពរណាស់ « ដោយឃើញពីគំរូដ៏ស្ងៀមស្ងាត់នៃសុភាពនារីម្នាក់ដែលកំពុងរស់នៅតាមដំណឹងល្អ » ។[6]

រឿងនេះឆ្លុះបញ្ចាំងពីការតាំងចិត្តរបស់យុវនារីយើងចំពោះបទដ្ឋានសាសនាចក្រ ។[7] វាក៏ជាគំរូនៃពួកអ្នកដឹកនាំយុវនារីដែលមានចិត្តខ្វល់ខ្វាយ និងមានការលះបង់នៅជុំវិញពិភពលោកផងដែរ ។ ពួកគេអស្ចារ្យណាស់!

បងប្អូនស្រីគ្រប់រូបមានតួនាទីសំខាន់ក្នុងសាសនាចក្រនិងគ្រួសារ ហើយគេម្នាក់ៗជាកត្តាដ៏សំខាន់ក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ។ ភាគច្រើនទំនួលខុសត្រូវទាំងនេះមិនបានផ្តល់ជាប្រាក់សម្រាប់ថ្លៃពលកម្មទេ តែវាផ្តល់ឲ្យនូវភាពរីករាយ ហើយវាមានសារៈសំខាន់ដ៏អស់កល្ប ។ ថ្មីៗនេះ មានស្ត្រីដ៏មានសមត្ថភាពម្នាក់ក្នុងក្រុមប្រឹក្សាផ្នែកនិពន្ធសារព័ត៌មានមួយបានសុំនូវការអធិប្បាយមួយពីតួនាទីរបស់ស្ត្រីក្នុងសាសនាចក្រនេះ ។ វាត្រូវបានពន្យល់ថា រាល់ពួកអ្នកដឹកនាំមិនបានទទួល*ប្រាក់កម្រៃ*ឡើយ ។ នោះនាងបាននិយាយកាត់ដោយលើកឡើងថាចំណាប់អារម្មណ៍របស់នាងត្រូវបានកាត់បន្ថយជាខ្លាំង ។ នាងនិយាយថា « ខ្ញុំមិនជឿថាស្ត្រីទូទៅត្រូវការការងារដែលគ្មានប្រាក់កម្រៃទៀតនោះទេ »

យើងបានគូសបញ្ជាក់ថា អង្គការដ៏សំខាន់បំផុតនៅលើផែនដីគឺជាគ្រួសារដែលមាន « ឪពុកម្តាយជា...ដៃគូស្មើភាពគ្នា » ។[8] គ្មាននរណាម្នាក់ទទួលប្រាក់កម្រៃឡើយ តែគេទទួលពរជ័យច្រើនហួសនឹងពាក្យថ្លែង ។ ពិតណាស់ យើងប្រាប់នាងពីអង្គការនៃសមាគមសង្គ្រោះ អង្គការយុវនារី និងអង្គការកុមារដែលត្រូវបានដឹកនាំដោយប្រធានជាស្ត្រី ។ ក្នុងប្រវត្តិសាស្ត្រយើង យើងបានសំគាល់ឃើញថា ទាំងបុរសទាំងស្ត្រីបានអធិស្ឋាន ប្រគំតន្ត្រី បង្រៀន និងច្រៀងក្នុងក្រុមចម្រៀង រួមទាំងក្នុងការប្រជុំសាក្រាម៉ង់ ដែលជាការប្រជុំដ៏ពិសិដ្ឋបំផុតរបស់យើង ។

សៀវភៅ*American Grace* ដែលមានការពេញនិយមជាខ្លាំងពេលថ្មីៗនេះ បានលើកឡើងពីស្ត្រីក្នុងសាសនាជាច្រើន ។ វាបានលើកឡើងថា ស្ត្រីអិល.ឌី.អេស.មានភាពអស្ចារ្យក្នុងភាពរីករាយជាខ្លាំងចំពោះតួនាទីរបស់ខ្លួនជាអ្នកដឹកនាំក្នុងសាសនាចក្រ ។[9] ជាងនេះទៀត ពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូប ទាំងប្រុសទាំងស្រីមានទំនាក់ទំនងយ៉ាងខ្លាំងបំផុតនឹងជំនឿរបស់យើងក្នុងការសិក្សាសាសនាជាច្រើន ។[10]

ស្ត្រីយើងមិនអស្ចារ្យដោយសារគេត្រូវបានគ្រប់គ្រងដើម្បីជៀសវាងពីភាពលំបាកក្នុងជីវិតនោះទេ ---វាគឺផ្ទុយស្រឡះ ។ គេមានភាពអស្ចារ្យដោយសារតែវិធីដែលគេប្រឈមនឹងការសាកល្បងនៃជីវិត ។ថ្វីបើឧបសគ្គ និងការសាកល្បងក្នុងជីវិតកើតចេញពីអាពាហ៍ពិពាហ៍ ឬការមិនបានរៀបការ ការជ្រើសរើសរបស់កូន សុខភាពអន់ថយ ខ្វះនូវឱកាស និងបញ្ហាជាច្រើនទៀតក្តី ក៏គេនៅតែរឹងមាំ និងមានភក្តីភាពនឹងសាសនារបស់គេដែរ ។ បងប្អូនស្រីយើងក្នុងសាសនាចក្របានជួយដល់អ្នកទន់ខ្សោយ លើកដៃដែលពោយ និងចំរើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រជានិច្ច ។[11] មានប្រធានសមាគមសង្គ្រោះម្នាក់ដែលបានទទួលស្គាល់ពីការបម្រើដ៏ល្អនេះ បាននិយាយថា « សូម្បីពេលបងប្អូនស្រីទាំងឡាយបានធ្វើការបម្រើក្តី ក៏គេកំពុងគិតថា ‹សង្ឃឹមថាខ្ញុំនឹងធ្វើអ្វីបានច្រើនជាងនេះទៀត ! ›» ថ្វីបើគេមិនល្អឥតខ្ចោះ ហើយជួបបញ្ហារៀងខ្លួនក្តី ក៏សេចក្តីជំនឿគេលើព្រះវរបិតាសួគ៌ជាទីស្រឡាញ់ និងលើការអះអាងនៃពលិកម្មដែលធ្វើឲ្យធួននៃព្រះអង្គសង្គ្រោះគឺកើតមាននៅក្នុងជីវិតរបស់គេជានិច្ច ។

រយៈពេលបីឆ្នាំនេះ គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានស្វែងរកការណែនាំ ការបំផុសគំនិត និងវិវរណៈ ពេលយើងប្រឹក្សាជាមួយនឹងពួកអ្នកដឹកនាំបព្វជិតភាព និងអង្គការជំនួយ ហើយរៀបចំនូវ*ក្បួនខ្នាត*ថ្មី។ ក្នុងដំណើរការនេះ ខ្ញុំបានដកពិសោធន៍នូវអារម្មណ៍នៃអំណរគុណជាខ្លាំងចំពោះតួនាទីដ៏សំខាន់ដែលបងប្អូនស្រីទាំងឡាយ ទាំងអ្នករៀបការនិងនៅលីវមាន ហើយឥឡូវបានដើរតួយ៉ាងសំខាន់ក្នុងគ្រួសារ និងក្នុងសាសនាចក្រ ។

រាល់សមាជិកគ្រប់រូបនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទត្រូវ « ធ្វើការងារនៅក្នុងចម្ការទំពាំងបាយជូររបស់ទ្រង់សម្រាប់សេចក្តីសង្គ្រោះដល់ព្រលឹងនៃមនុស្សលោក » ។[12] « កិច្ចការនៃសេចក្តីសង្គ្រោះ រួមមាន កិច្ចការផ្សព្វផ្សាយសាសនារបស់សមាជិក ការថែរក្សាសមាជិកថ្មី ការធ្វើឲ្យសមាជិកមិនសូវសកម្មមកសកម្មវិញ កិច្ចការព្រះវិហារបរិសុទ្ធនិងពង្សប្រវត្តិ ...ការបង្រៀនដំណឹងល្អ »[13] និងការមើលថែជនក្រីក្រ និងទុរគត ។[14] នេះត្រូវបានរៀបចំជាចម្បងនៅក្នុងក្រុមប្រឹក្សាវួដ ។[15]

ជាពិសេស ដោយយល់ដឹងពីបន្ទុកដ៏ធ្ងន់ដែលមានរួចហើយ ក្នុងក្បួនខ្នាតថ្មីត្រូវបានរៀបរៀងឡើងដើម្បីប៊ីស្សព នឹងចែករំលែកទំនួលខុសត្រូវច្រើន ។ សមាជិកត្រូវយល់ថា ប៊ីស្សពត្រូវបានណែនាំឲ្យធ្វើការចែករំលែក ។ សមាជិកត្រូវគាំទ្រ និងជួយគាត់ពេលគាត់ធ្វើតាមការប្រឹក្សានេះ ។ នេះនឹងអនុញ្ញាតឲ្យប៊ីស្សពមានពេលច្រើននឹងយុវវ័យ ពួកមជ្ឈិមវ័យនៅលីវវ័យក្មេង និងគ្រួសារគាត់ផ្ទាល់ ។ គាត់នឹងចែកទំនួលខុសត្រូវសំខាន់ផ្សេងទៀតដល់ពួកអ្នកដឹកនាំបព្វជិតភាព ប្រធានអង្គការជំនួយ យុវជនយុវនារីម្នាក់ៗ ។ ក្នុងសាសនាចក្រ តួនាទីរបស់ស្ត្រីនៅផ្ទះគឺមានការគោរពយ៉ាងខ្ពស់ ។[16] ពេលម្តាយទទួលការហៅមួយក្នុងសាសនាចក្រ ដែលតម្រូវឲ្យចំណាយពេលច្រើន នោះឪពុកជារឿយៗនឹងផ្តល់ឲ្យនូវការហៅដែលមិនទាមទារពេលច្រើន ដើម្បីរក្សាតុល្យភាពក្នុងជីវិតគ្រួសារ ។

ប៉ុន្មានឆ្នាំមុន ខ្ញុំបានចូលរួមក្នុងសន្និសីទស្តេកមួយនៅតុងហ្គា ។ នៅព្រឹកថ្ងៃអាទិត្យ កៅអីបីជួរមុខក្នុងសាលាប្រជុំគឺពេញដោយបុរសដែលមានអាយុពី26 ដល់ 35 ឆ្នាំ ។ ខ្ញុំបានគិតថាគេជាក្រុមចម្រៀងបុរស ។ តែពេលកិច្ចការក្នុងសន្និសីទនោះត្រូវបានធ្វើឡើង នោះបុរសទាំងនេះម្នាក់ៗ សរុប36 នាក់ បានក្រោកឈរ ពេលឈ្មោះគេត្រូវបានប្រកាសឡើយ ហើយត្រូវបានគាំទ្រសម្រាប់ការតែងតាំងបព្វជិតភាពមិលគីស្សាដែក ។ ខ្ញុំមានចិត្តរីករាយហើយភ្ញាក់ផ្អើល ។ បន្ទាប់ពីសម័យប្រជុំនេះ ខ្ញុំបានសួរប្រធាន ម៉ាតេអាគី ជាប្រធានស្តេកថាតើអព្ភូតហេតុនេះកើតឡើងដោយរបៀបណា ។ គាត់ប្រាប់ខ្ញុំថា ក្នុងការប្រជុំក្រុមប្រឹក្សាស្តេក ការធ្វើឲ្យសកម្មវិញត្រូវគេលើកមកពិភាក្សា ។ ប្រធានសមាគមសង្គ្រោះក្នុងស្តេកគាត់ បងស្រី លីណាតា វ៉ាអេនូគូ បានសួរថា វាសមរម្យដែរទេបើគាត់ចង់និយាយអ្វីមួយនោះ ។ ពេលគាត់និយាយ ព្រះវិញ្ញាណបានបញ្ជាក់ដល់ប្រធានថា អ្វីដែលគាត់បានលើកឡើងគឺពិត ។ គាត់បានពន្យល់ថា មានយុវជនដ៏ឆ្នើមមួយចំនួនធំដែលមានវ័យ 20 ឆ្នាំជិតចូល 30 ឆ្នាំ ក្នុងស្តេកដែលមិនបានចេញបម្រើបេសកកម្ម ។

គាត់និយាយថា ភាគច្រើនពួកគេបានដឹងថា គេបានធ្វើឲ្យប៊ីស្សព និងពួកអ្នកដឹកនាំបព្វជិតភាពដែលខំជំរុញពួកគេឲ្យចេញបម្រើខកចិត្ត ហើយឥឡូវនេះគេមានអារម្មណ៍ប្រៀបបាននឹងសមាជិកកម្រិតទីពីរក្នុងសាសនាចក្រ ។ គាត់លើកឡើងថា យុវជនទាំងនេះហួសអាយុបម្រើបេសកកម្មហើយ ។ គាត់បានសម្តែងក្តីស្រឡាញ់ និងកង្វល់របស់គាត់ចំពោះគេ ។ គាត់បានពន្យល់ថា រាល់ពិធីការសង្គ្រោះនៅតែមានតម្លៃសម្រាប់ពួកគេ ហើយការផ្តោតសំខាន់គួរតែទៅលើការតែងតាំងបព្វជិតភាព និងពិធីការក្នុងព្រះវិហារបរិសុទ្ធ ។ គាត់បានលើកឡើងថា ខណៈដែលយុវជនទាំងនេះមួយចំនួននៅលីវនៅឡើយ តែភាគច្រើនពួកគេបានរៀបការនឹងនារីល្អ ---ដោយសកម្មភាពមួយចំនួន អសកម្មមួយចំនួន និងមួយចំនួនទៀតពុំមែនជាសមាជិក ។

ក្រោយពីការពិភាក្សាដ៏ហ្មត់ចត់ក្នុងក្រុមប្រឹក្សាស្តេក គេបានសម្រេចថាបុរសក្នុងបព្វជិតភាព និងស្ត្រីក្នុងសមាគមសង្គ្រោះ ត្រូវជួយសង្គ្រោះបុរសទាំងនេះ និងភរិយាគេ ខណៈដែលប៊ីស្សពចំណាយពេលច្រើននឹងយុវនារីយុវជនក្នុងវួដ ។ អ្នកដែលចូលរួមក្នុងការសង្គ្រោះនេះបានផ្តោតសំខាន់លើការរៀបចំពួក

គេទទួលបព្វជិតភាព អាពាហ៍ពិពាហ៍អស់កល្ប និងពិធីការសង្គ្រោះក្នុងព្រះវិហារបរិសុទ្ធ ។ រយៈពេលពីរឆ្នាំក្រោយ បុរសទាំង 63 នាក់ដែលត្រូវបានគាំទ្រឲ្យទទួលបព្វជិតភាពមិលគីស្សាដែកក្នុងសន្និសីទដែលខ្ញុំបានចូលរួម ស្ទើរតែទាំងអស់បានទទួលអំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ ហើយបានផ្សារភ្ជាប់នឹងភរិយាខ្លួន ។ ដំណើររឿងនេះគឺគ្រាន់តែជាគំរូមួយនៃការខិតខំដែលបងប្អូនស្រីយើងមានក្នុងកិច្ចការសង្គ្រោះក្នុងវួដ និងស្តេកយើង និងរបៀបដែលពួកគេបានទទួលវិវរណៈ ជាពិសេសក្នុងក្រុមប្រឹក្សាសាសនាចក្រ ។[17]

យើងបានដឹងថា មានកម្លាំងដ៏ធំដែលត្រូវបង្កើតឡើងដើម្បីប្រឆាំងនឹងស្ត្រី និងគ្រួសារ ។ ការសិក្សាថ្មីៗនេះបានរកឃើញថា មាននូវការបដិសេធក្នុងការលះបង់ចំពោះអាពាហ៍ពិពាហ៍ ដោយមានចំនួននៃពួកមជ្ឈិមវ័យដែលចង់រៀបការធ្លាក់ចុះ ។[18] ចំពោះមនុស្សមួយចំនួន អាពាហ៍ពិពាហ៍និងគ្រួសារកំពុងប្រែក្លាយជា « ការជ្រើសរើស ផ្ទាល់ ខ្លួនជាជាងគោលការណ៍រៀបចំដ៏សំខាន់សម្រាប់សង្គមយើងទៅវិញ » ។[19] ស្ត្រីត្រូវប្រឈមមុខនឹងជម្រើសជាច្រើន ហើយត្រូវគិតយ៉ាងហ្មត់ចត់ពីជម្រើសដែលពួកគេធ្វើ និងផលប៉ះពាល់របស់វាដល់គ្រួសារ ។

ពេលខ្ញុំនៅ នូហ្សីឡង់ កាលពីឆ្នាំមុន ខ្ញុំបានអានសារព័ត៌មានពីស្ត្រីឈ្មោះ អូកឡិន ដែលមិនមែនជារបស់សាសនាយើង ។ មានម្តាយម្នាក់បាននិយាយថា គាត់បានដឹងថាក្នុងករណីរបស់គាត់ ជម្រើសរបស់គាត់នៅក្នុងការធ្វើការ ឬនៅផ្ទះគឺវាប្រហាក់ប្រហែលនឹងកម្រាលព្រំថ្មីមួយ និងឡានទីពីរដែលគាត់មិនត្រូវការឡើយ ។ តែ មានម្តាយម្នាក់ទៀត មានអារម្មណ៍ថា សត្រូវដ៏ធំបំផុតនឹង «ជីវិតគ្រួសារដ៏មានសុភមង្គលមិនមែនជាការងារទេ ---វាជាទូរទស្សន៍ » ។ គាត់បាននិយាយថា គ្រួសារដែលចំណាយពេលច្រើនមើលទូរទស្សន៍ នឹងគ្មានពេលសម្រាប់គ្រួសារឡើយ ។[20]

ទាំងនេះគឺជាការសម្រេចចិត្តផ្ទាល់ខ្លួន តែមានគោលការណ៍ពីរដែលយើងគប្បីចងចាំជានិច្ច ។ ទីមួយ មិនគួរមានស្ត្រីណាម្នាក់មានអារម្មណ៍ចង់សុំទោស ឬមានអារម្មណ៍ថាខ្លួនមិនសូវសំខាន់ ដោយសារនាងកំពុងខិតខំបំពេញកិច្ចការដ៏សំខាន់របស់ខ្លួនក្នុងការចិញ្ចឹមបីបាច់កូនចៅនោះឡើយ ។ នៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌យើងគឺគ្មានអ្វីដែលសំខាន់ជាងនេះឡើយ ។ ទីពីរ យើងទាំងអស់គ្នាត្រូវប្រុងប្រយ័ត្ន ដោយកុំវិនិច្ឆ័យ ឬសន្មតថា បងប្អូនស្រីទាំងឡាយខ្វះនូវភាពក្លាហាន បើពួកគេសម្រេចចិត្តទៅធ្វើការខាងក្រៅនោះ ។ យើងកម្រយល់ ឬដឹងគុណដោយអស់ពីចិត្តចំពោះស្ថានភាពរបស់មនុស្សទូទៅណាស់ ។ ស្វាមីនិងភរិយាទាំងឡាយគប្បីប្រឹក្សារួមគ្នាដោយហ្មត់ចត់ ដើម្បីយល់ថាពួកគេទទួលខុសត្រូវចំពោះការសម្រេចចិត្តគេ ។

បងប្អូនស្រីទាំងឡាយដែលជាម្តាយទោល ទោះជាដោយហេតុផលណាក្តី យើងមានអំណរគុណដល់អ្នកខ្លាំងណាស់ ។ ពួកព្យាការីបានបញ្ជាក់ច្បាស់ថា « មានមនុស្សជាច្រើនដែលរៀបខ្លួនជាស្រេចដើម្បីជួយអ្នក ។ ព្រះអម្ចាស់មិនបានបំភ្លេចអ្នកឡើយ ។ រួមទាំងសាសនាចក្រទ្រង់ដែរ » ។[21] ខ្ញុំសង្ឃឹមថា ពួកបរិសុទ្ធថ្ងៃចុងក្រោយនឹងនាំមុខគេក្នុងការបង្កើតបរិយាកាសមួយក្នុងកន្លែងការងារ ដែលរីករាយចំពោះស្ត្រីនិងបុរសក្នុងទំនួលខុសត្រូវរបស់ខ្លួនជាឪពុកម្តាយ ។

បងប្អូនស្រីដ៏ក្លាហាននិងស្មោះត្រង់ សូមដឹងថា យើងស្រឡាញ់ ហើយអរគុណអ្នក ហើយសូមអះអាងដល់អ្នកថា គ្មានពរជ័យណាមួយនឹងត្រូវបានដកយកពីអ្នកឡើយ ។

ស្ត្រីត្រួសត្រាយផ្លូវដ៏អស្ចារ្យ អិមមីលី អេជ វូដមេនស៊ី បាននិពន្ធទំនុកច្រៀងនៃទំនុកតម្កើង « As Sisters in Zion »។ គាត់ពោលអះអាងដ៏ត្រឹមត្រូវថា « ភារកិច្ចរបស់ពួកទេវតាត្រូវបានប្រទានឲ្យដល់ស្ត្រីទាំងឡាយ » ។ នេះបានរៀបរាប់ថា« គ្មានអ្វីប្រសើរជាងការធ្វើកិច្ចការភ្លាមស្របតាមការស្នើសុំរបស់ព្រះវរបិតាសួគ៌យើងឡើយ ហើយ ‹ នេះជាអំណោយទានមួយដែល...បងប្អូនស្រី...ទាមទារ› »។[22]

បងប្អូនស្រីជាទីស្រឡាញ់ យើងស្រឡាញ់ហើយកោតសរសើរដល់អ្នក ។ យើងអរគុណចំពោះការបម្រើរបស់អ្នកក្នុងនគរព្រះអម្ចាស់ ។ អ្នកអស្ចារ្យណាស់ ! ខ្ញុំសូមសម្តែងការដឹងគុណជាពិសេសចំពោះស្ត្រីក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ពីភាពពិតនៃដង្វាយធួន ដែលជាទេវភាពនៃព្រះអង្គសង្គ្រោះ និងការស្តារឡើងវិញនៃសាសនាចក្រទ្រង់ ។ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Wallace Stegner, *The Gathering of Zion* ( McGraw-Hill Book Company ឆ្នាំ 1971 ) ទំព័រ 13 ។

2. Robert D. Putnam and David E. Campbell, *American Grace: How Religion Divides and Unites Us*, Simon & Schuster ឆ្នាំ 2010 ទំព័រ 233 ។

3. សូមមើល *Handbook 2: Administering the Church* វគ្គ 1.3.1 ។ សូមមើល ម៉ូសេ 5:1, 4, 12, 27 ផងដែរ ។

4. *The Story of the Martin Handcart Pioneers* ទំព័រ 445 ។

5. « Leaves From the Life of Elizabeth Horrocks Jackson Kingsford » Historical Society, Manuscript ទំព័រ A 719 ។ « Remembering the Rescue » *Ensign* ខែ សីហា ឆ្នាំ 1997 ទំព័រ 38 ។

6. ដំណើររឿងពីកាបូបដៃ រំបាំនៅយប់មុនថ្ងៃចូលឆ្នាំថ្មី រួមមានស្តេកMission Viejo Stake, ស្តេកLaguna Nigel, ស្តេកSan Clemente, ស្តេកRancho Margarita ទាំងអស់នៅរដ្ឋCalifornia បានរៀបរៀងនឹងកែសម្រួលពីអ៊ីមែលមួយដែលសរសេរដោយSister Monica Sedgwick ប្រធានយុវនារីស្តេក Laguna Nigel និងការនិយាយដ៏ខ្លីមួយរបស់ Sister Leslie Mortensen ប្រធានយុវនារីស្តេក Mission Viejo Stake នៅថ្ងៃទី 20 ខែ មករា ឆ្នាំ 2011 ។

7. ក្នុងអត្ថបទដែលមានចំណងជើងថា « Why Do We Let Them Dress Like That ? » សារព័ត៌មាន *The Wall Street Journal,* ចុះថ្ងៃសៅរ៍ទី 19-20 ខែ មិនា ឆ្នាំ 2011 ទំព័រ C3 មានម្តាយជនជាតិយូដាម្នាក់បានគាំទ្រដល់បទដ្ឋាននៃការស្លៀកពាក់ និងសីលធម៌ និងបានទទួលស្គាល់ពីគំរូនៃស្ត្រីមរមន ។

8. *ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក ។*

9. *American Grace* ទំព័រ 244–5 ។

10. *American Grace* ទំព័រ 504។

11. សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា 81:5 សូមមើលម៉ូសាយ 4:26 ផងដែរ ។

12. គោលលទ្ធិ និង សេចក្តីសញ្ញា 138:56 ។

13. *Handbook 2: Administering the Church* ឆ្នាំ 2010 ជំពូក 5 « The Work of Salvation in the Ward and Stake » ។

14. សូមមើល *Handbook 2*, ជំពូក 6 « Welfare Principles and Leadership » ។

15. សូមមើល *Handbook 2* ជំពូក 5 « The Work of Salvation in the Ward and Stake » ។

16. Emily Matchar « Why I can't stop reading Mormon housewife blogs » Salon.com.Mobile ថ្ងៃទី15 ខែ មករា ឆ្នាំ 2011 ។ អ្នកការពារដល់សិទ្ធស្ត្រី និងមិនជឿព្រះរូបនេះបានទទួលស្គាល់ការគោរពនេះ ហើយបាននិយាយថានាងចូលចិត្តអានកំណត់ហេតុបណ្តាញរបស់ពួកមរមនពីស្ត្រីមេផ្ទះ ។

17. Tonga Ha'akame Stake, Stake President Lehonitai Mateaki ( ក្រោយមកបានបម្រើជាប្រធានបេសកកម្ម Papua New Guinea )។ ប្រធានសមាគមសង្គ្រោះស្តេក Leinata Va'enuku ។

18. PEW Resource Center, Social & Demographic Trends ។ ចំនួនទារកដែលកើតមកក៏មានការធ្លាក់ចុះយ៉ាងខ្លាំងផងដែរនៅក្នុងប្រទេសជាច្រើន ។ នេះត្រូវបានហៅថា Demographic Winter ។

19. Deseret News Editorial ថ្ងៃទី 22 ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ A14 ដកស្រង់ចេញពីសេចក្តីរាយការណ៍មួយនៅ MSNBC.com ។

20. *The Herald* ថ្ងៃចន្ទ ទី 1 ខែកុម្ភៈ ឆ្នាំ 2010 ទំព័រ A2 Collins, Simon « Put Family Before Money Making » ។

21. Gordon B. Hinckley *The Teachings of Gordon B. Hinckley* ទំព័រ 601 ។ Spencer W. Kimball « Our Sisters in the Church » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1979 ។

22. Karen Lynn Davidson, Our Latter-day Hymns: The Stories and The Messages, ( Bookcraft, Salt Lake City ឆ្នាំ 1988 ) ទំព័រ 309 ។